# បូជនីយដ្ឋាន និង ការចងចាំ : អណ្តូងស្រះមោល

*សែមុ៉ន ក្រូស៊ី និង ចច វ៉ាយត៍*

*ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣*

*ប្រែសម្រួលដោយ ញាណ សុជាតិ*

មិនឆ្ងាយប៉ុន្មាន បូជនីយដ្ឋានមួយអាចមើលពីទីរួមខេត្តបាត់ដំបង ។ មានទីតាំងនៅលើវាលមួយខាងក្រោយវត្ត មានសំណង់បូជនីយដ្ឋានរាងចតុកោណមួយ ដែលមានបង្អួចកញ្ចក់នៅជុំវិញ និងមានសំណល់ឆ្អឹងមនុស្សដែលបានស្លាប់ក្នុងរបបខ្មែរក្រហមពេញនៅក្នុងនោះ ។ នៅជុំវិញបូជនីយដ្ឋាននោះមានចម្លាក់ថ្មជាច្រើនដែលរៀបរាប់អំពីហេតុការណ៍កាលពីរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជា ។ នៅជិតបូជនីយដ្ឋាននោះជាវត្តសំរោងក្នុង គឺជាវត្តមួយដែលខ្មែរក្រហមធ្លាប់ប្រើប្រាស់ជាគុកនិងជាទីតាំងសួរចម្លើយ ។ អក្សរចរិកនៅលើបូជនីយដ្ឋាននោះ បានរៀបរាប់ថា មនុស្សចំនួន១០០.០៨ត្រូវបានសម្លាប់នៅទីនោះ ។ អ្វីដែលគួរឲ្យរន្ធត់នោះគឺថា អ្នកស្រុកដែលរស់នៅទីនោះបាននិយាយថា ឆ្អឹង និងលលាដ៏ក្បាលដែលតាំងនៅក្នុងបូជនីយដ្ឋាននោះត្រូវបានគាស់ចេញពីរណ្តៅមួយដែលជាគ្រឹះរបស់បូជនីយដ្ឋាននេះតែម្តង ។ ពេលយើងនិយាយអំពីប្រវត្តិបូជនីយដ្ឋានទៅកាន់អាចារ្យ និងដូនជីនៅវត្តនោះ គាត់បានប្រាប់យើងថា ជាទូទៅមានបរទេសខ្លះបានមកទស្សនាបូជនីយដ្ឋាននេះដែរ ។ អាចារ្យនិងដូនជីបាននិយាយទៀតថា សាច់ញាតិរបស់អ្នកដែលបានស្លាប់ក៏បានមកទស្សនាទីតាំងនេះ និងបានយកផ្កាមកបូជាដែរតែកម្រមានណាស់ ។

ចម្ងាយប្រមាណជា១០០គីឡូម៉ែត្រពីវត្តសំរោងក្នុង តាមផ្លូវជាតិលេខ៥៧ គឺជាទីរួមខេត្តប៉ៃលិន ។ ទីតាំងខេត្តប៉ៃលិន គឺជាតំបន់ដែលធ្លាប់គ្រប់គ្រងដោយកងទ័ពដែលស្មោះនឹងមេដឹកនាំខ្មែរក្រហម អៀង សារី ។ អៀង សារី បានផ្តាច់ខ្លួនចូលមករួមរស់ជាមួយរដ្ឋាភិបាល និងទទួលបាននូវការអភ័យទោស និងការលើកលែងទោសពីសំណាក់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ក្នុងឆ្នាំ១៩៩៦ ។ ក្រោយពីចុះចូលជាមួយរដ្ឋាភិបាល កងទ័ពខ្មែរក្រហមជាច្រើនបានផ្លាស់ប្តូរជីវិតពីកងទ័ពមកជាប្រជាជនស៊ីវិលវិញ និងបានរស់នៅក្នុងទីតាំងដដែលគឺខេត្តប៉ៃលិននេះ ។ សព្វថ្ងៃ ភាគច្រើននៃអ្នកទាំងអស់នេះ កំពុងរស់នៅទីនេះ ។ ទោះបីជារបបខ្មែរក្រហមដួលរលំហើយក៏ដោយ ផ្នត់គំនិត “អង្គការ” នៅតែឋិតនៅក្នុងចិត្តនិងការគិតរបស់អតីតកម្មាភិបាលខ្មែរក្រហមនោះនៅឡើយ ។ នៅខេត្តប៉ៃលិននេះ យើងបានជួបប្រទះនូវភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងអ្នកដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម និងក្មេងដែលកើតក្រោយរបបនេះ ។

*កើតក្នុងឆ្នាំ១៩៧៧ អតីតកម្មាភិបាលខ្មែរក្រហមម្នាក់មានអាយុជាងមួយឆ្នាំ ប៉ុណ្ណោះពេលដែលរបបខ្មែរក្រហមដួលរលំក្នុងខែមករាឆ្នាំ១៩៧៩ ។ ប៉ុន្តែ អតីតកម្មាភិបាលខ្មែរក្រហមរូបនេះនៅតែរៀបរាប់ថា របបខ្មែរក្រហមជារបបមួយដែលមិនមានជំងឺអេដស៍ ពេស្យាចារ្យ និងអំពើឆក់ប្លន់នានាឡើយ ។ ស្ថិតក្នុងសម្លៀកបំពាក់យោធាខ្មែរក្រហមផ្តល់ជំនួយដោយចិនកាលពីទសវត្សរ៍៨០ អតីតកម្មាភិបាលខ្មែរក្រហមរូបនោះបានបង្ហាញនូវការកោតសរសើរយ៉ាងជ្រាលជ្រៅដល់មនោគមវិជ្ជាខ្មែរក្រហម ព្រមទាំងបានព្យាយាមបកស្រាយអំពីហេតុការណ៍កាប់សម្លាប់ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។*

*កម្មាភិបាលរូបនោះបាននិយាយថា "សង្គមកម្ពុជាហាក់បីដូចជាកសិដ្ឋានមួយអ៊ីចឹង ។ នៅពេលដែលកសិដ្ឋាននោះមានសត្វពាហនៈច្រើនណែនណាន់តាន់តាប់ពេក សត្វពាហនៈដែលមិនសូវល្អ ហើយម្ចាស់មិនសូវពេញចិត្ត និងត្រូវសម្លាប់ចោលដើម្បីការពារសត្វពាហនៈផ្សេងទៀត" ។ កម្មាភិបាលរូបនោះ គាំទ្រនូវកិច្ចប្រឹងប្រែងរបស់ខ្មែរក្រហមយ៉ាងពេញទំហឹងដែលបានលុបបំបាត់ចោលនូវជំងឺសង្គម ។ គាត់បានបន្តថា "ក្នុងរបបខ្មែរក្រហមមិនមានស្រីពេស្យាចារ្យ មិនមានជំងឺអេដស៍ និងមិនមានអំពើឆក់ប្លន់ទេ ។ ខ្ញុំគិតថា នេះគឺជាចំណុចល្អមួយ" ។ ទោះបីជាគាត់គិតថារបបខ្មែរក្រហមល្អបែបនេះក៏ដោយក៏គាត់ទទួលស្គាល់ថា របបខ្មែរក្រហមបានសម្លាប់មនុស្សជាច្រើនដែល"ជារឿងពិបាកនឹងជឿដែលថាខ្មែរក្រហមសម្លាប់មនុស្សច្រើនបែបនេះ" ។*

*នៅពេលសួរអំពីអារម្មណ៍របស់គាត់អំពីថ្នាក់ដឹកនាំរបស់ខ្មែរក្រហម អតីតកម្មាភិបាលរូបនេះបានឆ្លើយថា ការដាក់ឲ្យមានការទទួលខុសត្រូវចំពោះតែអ្នកដែលមានដំណែងខ្ពស់បំផុតនោះ ហាក់ដូចជាអ្វីដែល តាម៉ុក ធ្លាប់និយាយថា "ស៊ីមួយតុឲ្យ តាម៉ុក ចេញលុយតែម្នាក់ឯង!" ។ តាម៉ុក គឺជាអតីតមេបញ្ជាការខ្មែរក្រហមដ៏អសោចម្នាក់ដែលបានស្លាប់ក្នុងឆ្នាំ២០០៦ពេលកំពុងតែរង់ចាំការកាត់ទោស ។*

*ការឈរទល់មុខគ្នាដូច្នេះជាមួយអតីតទាហានខ្មែរក្រហម ម្នាក់ដែលបានរៀបរាប់ពីការសម្លាប់ដោយឈរនៅលើកំពូលភ្នំដ៏ស្រស់ស្អាតបែបនេះហាក់បីដូចជារឿងចម្លែកមួយ ហើយប៉ៃលិនធ្លាប់ជាតំបន់ដែលធ្លាប់គ្រប់គ្រងដោយខ្មែរក្រហមដែលជាអ្នកសម្លាប់មនុស្ស ។*

*តំបន់ប៉ៃលិននេះ គឺជាទីតាំងមួយ នៃក្រុមមួយដែលបង្កឲ្យមានអំពើឃោរឃៅដ៏ធំក្នុងសតវត្សរ៍ទី២០នេះ ។*

**-ចប់-**